គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ច័ន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ខូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូច ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុគ កែវសុត្ថា

លេខ ១០១៤ /សសគម/២០

# សេចក្តីសម្រេច

## ស្តីពី

## ការចុះបញ្ជីនិងការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសម្រាប់មេធាវីបរទេស ដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធមិមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

## ស ម្រេ ច

**ប្រការ១** .. មេធាវីបរទេសដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវចុះបញ្ជីជាមុនជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២** .. មេធាវីបរទេសដែលបំពេញបានតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ប្រការ៣** .. អង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុង



អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

តុលាការកម្ពុជា ត្រូវពិនិត្យផ្ទៀងផ្ទាត់និងបកប្រែឯកសារទាំងអស់របស់មេធាវីបរទេសមកជាភាសាខ្មែរនិងទទួលខុសត្រូវលើការបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនីមួយៗ។ ក្នុងករណីពិនិត្យឃើញថាពាក្យសុំនោះបានបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់ហើយ អង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបញ្ជូនសំណុំឯកសារនោះមកគណៈមេធាវី។

**ប្រការ៤**.- គណៈមេធាវីត្រូវពិនិត្យនិងសម្រេចលើពាក្យសុំនោះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសំណុំឯកសារត្រឹមត្រូវ លើកលែងតែករណីដែលមិនអាចជម្នះបាន។

**ប្រការ៥**.- ក្នុងករណីគណៈមេធាវីសម្រេចចុះបញ្ជីមេធាវីបរទេសណាមួយ គណៈមេធាវីត្រូវជូនដំណឹងទៅមេធាវីបរទេសរូបនោះតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឱ្យបង់ប្រាក់ថ្លៃចុះបញ្ជីចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុងរយៈពេលកំណត់ជាក់លាក់មួយ។ ក្នុងករណីមេធាវីបរទេសពុំបានបង់ប្រាក់ថ្លៃចុះបញ្ជីតាមការកំណត់ទេ សេចក្តីសម្រេចចុះបញ្ជីមេធាវីបរទេសរូបនោះត្រូវលុបចោលជាស្វ័យប្រវត្តិ។ ក្នុងករណីមេធាវីបរទេសបានបង់ប្រាក់តាមការកំណត់ គណៈមេធាវីត្រូវស្នើសុំកម្មវិធីធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ។ មេធាវីបរទេសត្រូវមានវត្តមានតាមការកំណត់របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**ប្រការ៦**.- មេធាវីបរទេសត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមកគណៈមេធាវីក្នុងរយៈពេល១(មួយ)សប្តាហ៍ បន្ទាប់ពីធ្វើសច្ចាប្រណិធាន ដោយភ្ជាប់មកជាមួយនូវរូបថតពាក់អាវវិជ្ជាជីវៈទំហំ៤គុណ៦ចំនួន២(ពីរ)សន្លឹក។ វិញ្ញាបនបត្រនេះមានសុពលភាព១(មួយ)ឆ្នាំ។

**ប្រការ៧**.- មេធាវីបរទេសដែលមានបំណងបន្តចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវផ្តល់ឯកសារបញ្ជាក់អំពីសុពលភាពនៃការចុះឈ្មោះរបស់ខ្លួនក្នុងបញ្ជីគណៈមេធាវីដែលត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ហើយដែលមានកេរ្តិ៍ឈ្មោះល្អច្បាប់ដើមឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជាក់ដោយអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការបកប្រែជាភាសាខ្មែរ មកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានយ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃ មុនពេលវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអស់សុពលភាព។ ឯកសារនេះអាចដាក់ដោយមេធាវីបរទេសផ្ទាល់ ឬតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ក្នុងករណីមិនបានផ្តល់ឯកសារបញ្ជាក់ពីសុពលភាពតាមកាលកំណត់នេះទេ នោះគណៈមេធាវីនឹងសម្រេចលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី។

**ប្រការ៨**.- មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មុនចេញសេចក្តីសម្រេចនេះ ត្រូវផ្តល់ឯកសារបញ្ជាក់អំពីសុពលភាពនៃការចុះឈ្មោះរបស់ខ្លួនក្នុងបញ្ជីគណៈមេធាវីដែលត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ហើយដែលមានកេរ្តិ៍ឈ្មោះល្អច្បាប់ដើមឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជាក់ដោយអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការបកប្រែជាភាសាខ្មែរ ដោយភ្ជាប់មកជាមួយនូវរូបថតពាក់អាវវិជ្ជាជីវៈទំហំ៤គុណ៦ចំនួន២(ពីរ)សន្លឹក មកគណៈមេធាវីឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ដើម្បីធ្វើ

បច្ចុប្បន្នភាពនិងផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឯកសារនេះអាចដាក់ដោយមេធាវីបរទេសផ្ទាល់ ឬតាមរយៈអង្គភាពគាំពារការពារក្តីឬអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្នុងករណីមិនបានផ្តល់ឯកសារបញ្ជាក់ពីសុពលភាពតាមកាលកំណត់នេះទេ នោះគណៈមេធាវីត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី ។

**ប្រការ៩** .- សេចក្តីសម្រេចលេខ៦៩៤/សសគម/១៨ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈ និងកាតព្វកិច្ចបង់ភាគទានរបស់មេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១០** .- អគ្គលេខាធិការគណៈមេធាវីនិងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ច័ន្ទ ៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២០

**ប្រធាន**

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី លី-ច័ន្ទតុលា

***ចម្លងជូន***

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ដូចប្រការ១០

-ឯកសារ-កាលប្បវត្តិ